# ធាតុចូលពីអង្គការសង្គមស៊ីវិល
# លើការស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

១. សវតា

អង្គការសង្គមស៊ីវិល ដែលកំពុងប្រតិបត្តិការការងារលើវិស័យផ្សេងគ្នាៗនៅប្រទេសកម្ពុជា យ៉ាងហោចណាស់ចំនួន ៥០០ អង្គការ និងសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដែលជាអង្គការសមាជិក បណ្តាញ និងដៃគូ បានឯកភាពគ្នាដាក់ធាតុចូលលើការស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ អង្គការសង្គមស៊ីវិលជាតំណាងដៃគូ ដែលមានសមាជិកយ៉ាងតិច ៥០០ នេះរួមមាន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អង្គការ និងសមាគម ក្រោមការសម្របសម្រួលរបស់អង្គការគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សម្ព័ន្ធសិទ្ធិកុមារកម្ពុជា ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច អង្គការជួយផ្នែកច្បាប់នៃកម្ពុជា សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងអង្គការ សមាគមយុវជនមួយចំនួនទៀត ស្នើឲ្យមានការធ្វើវិសោធនកម្មលើមាត្រាមួយចំនួននៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយមូលហេតុថា មាត្រាមួយចំនួន និងបទប្បញ្ញត្តិមួយចំនួននៃច្បាប់នេះ បានជះឥទ្ធិពលដោយផ្ទាល់លើការបំពេញការងារ និងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល ក្នុងការតស៊ូមតិដើម្បីលើកកម្ពស់សិទ្ធិមនុស្ស តម្លាភាព និងគណនេយ្យភាពសង្គម។ មិនតែប៉ុណ្ណោះ ច្បាប់នេះក៏ជាឧបសគ្គចំពោះ លំហសេរីភាពសង្គមស៊ីវិល និងដំណើរការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

ធាតុចូលនេះ ជាលទ្ធផលនៃការប្រជុំពិគ្រោះយោបល់ដោយមានការចូលរួមពី អង្គការសង្គមស៊ីវិល ប្រមាណ ៥០០ អង្គការសមាគម មិនមែនរដ្ឋាភិបាលតាមរយៈ សិក្ខាសាលា វេទិកាពិគ្រោះយោបល់ ការវិភាគ ការស្ទង់មតិ និងកិច្ចពិភាក្សាក្នុងភាពជាដៃគូទាំងនៅកម្រិតជាតិ និងថ្នាក់ក្រោមជាតិ។ ការប្រមូលចងក្រងករណីសិក្សាអំពីបញ្ហាប្រឈមលើការអនុវត្តន៍ច្បាប់នេះ ដែលទទួលបានពីអង្គការសង្គមស៊ីវិលនានា ព្រមទាំងការវិភាគច្បាប់យ៉ាងល្អិតល្អន់លើខ្លឹមសារនៃមាត្រាទាំងឡាយ និងការអនុវត្តន៍ជាក់ស្តែងនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងរយៈពេលជិត ៥ឆ្នាំកន្លងមកនេះ។ លើសពីនេះ តំណាងនៃអង្គការសង្គមស៊ីវិលប្រមាណជា៥០០បានចូលរួមជជែកដេញដោលយ៉ាងសកម្ម និងតាមដានការធ្វើបច្ចុប្បន្នភាពក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាសំណើ អនុសាសន៍ រវាងអង្គការសង្គមស៊ីវិលជាមួយក្រុមការងារនៃក្រសួងមហាផ្ទៃ ដែលមាន ឯកឧត្តម ប៊ិន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល

ដើម្បីប្រមូលធាតុចូល និងមតិយោបល់រួមពីអង្គការសង្គមស៊ីវិលស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រព្រឹត្តិទៅនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ និងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ នៅទីស្តីក្រសួងមហាផ្ទៃ។

តាមស្មារតីនៃកិច្ចប្រជុំលើកទីពីរ និងដើម្បីចូលរួមកិច្ចប្រជុំលើកទី៣ (បី) ដែលត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ តំណាងក្រុមការងារនៃអង្គការសង្គមស៊ីវិលដែលបានដាក់ធាតុចូល និងមតិយោបល់លើសេចក្តីស្នើធ្វើវិសោធនកម្មច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានដាក់ជូននូវឯកសារពង្រាងទី២ ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានឯកភាពថាចាំបាច់ត្រូវធ្វើវិសោធនកម្មលើបទប្បញ្ញត្តិចំនួន ១៥មាត្រា ក្នុងនោះមានពីរមាត្រា (មាត្រា ២៤ និង ៣២) គឺស្នើលុបទាំងស្រុង។ បន្ថែមពីលើនេះ ក្រុមការងារនៃអង្គការសង្គមស៊ីវិលសង្ឃឹមថា កិច្ចប្រជុំលើកទី៣ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២០ ខាងមុខនេះ នឹងពិភាក្សាលម្អិតលើធាតុចូលនេះ ព្រមទាំងអំពីផែនទីបង្ហាញផ្លូវ (Roadmap) ទាក់ទងនឹងដំណើការនៃការធ្វើវិសោធនកម្មច្បាប់នេះ។

២. សេចក្តីផ្តើម

កិច្ចព្រមព្រៀងទីក្រុងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានក្លាយជាមូលដ្ឋានសម្រាប់ឲ្យមានព្រះរាជាណាចក្រកម្ពុជាទី២ ដែលមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូល ហើយបានចែងយ៉ាងច្បាស់ថា ព្រះរាជាណាចក្រកម្ពុជាប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដែលមានព្រះមហាក្សត្រគ្រងរាជ្យសម្បត្តិ តែមិនកាន់អំណាច ហើយអំណាចទាំងអស់គឺជារបស់ប្រជាពលរដ្ឋខ្មែរ។ ប្រជាពលរដ្ឋ គឺជាម្ចាស់វាសនាប្រទេសជាតិរបស់ខ្លួន។ អំណាចរបស់ប្រជាពលរដ្ឋប្រើតាមរយៈអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។

ក្រៅពីភាពជាម្ចាស់អំណាចទាំងអស់ មាត្រា៤២ នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមកការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។ ក្រោមរដ្ឋធម្មនុញ្ញជាធរមាននេះ ក្រសួងមហាផ្ទៃបានសម្របសម្រួលដោយចេញប្រកាសលេខ៨៧៤សជណ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៤ សម្រាប់ជាបែបបទចុះបញ្ជីសមាគម។ តាមប្រកាសនេះ ការកកើតនូវសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាក៏ចាប់ផ្តើមមាន និងមានជាថ្មីនៅកម្ពុជា។

នៅឆ្នាំ២០១៥ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើចូលជាធរមាន ហើយបាននឹងកំពុងអនុវត្តបានជាង ៤ឆ្នាំមកហើយ គិតមកដល់បច្ចុប្បន្ន។ បន្ទាប់ពីច្បាប់នេះបានចូលជាធរមាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន

បាននឹងកំពុងជួបប្រទះបញ្ហាប្រឈមចម្បងៗមួយចំនួន ដូចជាៈ នីតិវិធីនៃការចុះបញ្ជី ការផ្លាស់ប្តូរថ្នាក់ដឹកនាំ និងអាសយដ្ឋាន ការបើកគណនេយ្យធនាគារ ការបំពេញកាតួកិច្ចពន្ធដារ និងការដាក់ជូនរបាយការណ៍ រួមទាំងការលាបពណ៌ខាងនយោបាយ។

សេចក្តីវិភាគនេះបញ្ជាក់ពីការប្រឈមចំពោះការអនុវត្តន៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលលើអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា ។ សេចក្តីវិភាគនេះផ្តល់ជាមូលដ្ឋានស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ ជាកំណត់សម្គាល់ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០២០កន្លងមកថ្មីៗនេះដែរ អង្គការសង្គមស៊ីវិលចូលរួមចំនួន២៩អង្គការ សមាគម ក៏បានលើកឡើងនូវកង្វល់ចំៗចំនួន៥ គឺៈ (១)ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (២) របាយការណ៍ និងការជូនដំណឹង (៣) បន្ទុកនៃការបំពេញឯកសារបង់ពន្ធដា (៤) ពាក្យអព្យាក្រឹតភាពពីគណបក្សនយោបាយ ក៏ដូចជាពាក្យប៉ះពាល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងវប្បធម៌ប្រពៃណីល្អ និង (៥) សង្គមស៊ីវិលនៅតែទាមទារឱ្យមានការអនុវត្តន៍ឱ្យបានត្រឹមត្រូវនូវមាត្រាមួយចំនួនតាមកំណត់នៃច្បាប់ និងការបើកសេរីភាពពិតប្រាកដចំពោះការធ្វើសកម្មភាពនៅមូលដ្ឋាន។

៣. គោលបំណងនៃការស្នើសុំធ្វើវិសោធនកម្ម និងការកែលម្អការអនុវត្តន៍

១. ធ្វើឱ្យច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានសង្គតិភាពជាមួយរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធផ្សេងៗ

២. លើកកម្ពស់សិទ្ធិស្វ័យភាពនីតិបុគ្គលសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ស្របតាមគោលការណ៍សិទ្ធិមនុស្ស រដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណី

៣. កែលម្អការអនុវត្តន៍មួយចំនួន ឱ្យស៊ីសង្វាក់គ្នាជាមួយមាត្រាច្បាប់ដែលបានចែង ។

៤. វិធីសាស្ត្រ

ឯកសារធាតុចូលពីអង្គការសង្គមស៊ីវិលចំពោះការស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ រៀបចំឡើងតាមវិធីសាស្ត្រដូចខាងក្រោមៈ

- ជួបប្រជុំគ្នារវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលបាននិងកំពុងប្រតិបត្តិការនៅកម្ពុជា ។ អង្គការសង្គមស៊ីវិលបានរៀបចំវេទិកាពិគ្រោះយោបល់ និងសិក្ខាសាលាពហុភាគីស្តីពីការអនុវត្តន៍ និងបញ្ហាប្រឈមនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ វេទិកាពិគ្រោះយោបល់ និងសិក្ខាសាលាទាំងនេះ មានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗគ្នា ដូចជា សង្គមស៊ីវិលដៃគូអភិវឌ្ឍន៍ បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត អង្គការសហគម ជាអាទិ៍ ដើម្បីធ្វើការកំណត់បញ្ហា ពិភាក្សា

និងចែករំលែកនូវធាតុចូលសំខាន់ៗពាក់ព័ន្ធនឹងសកម្មភាព ការងាររបស់ខ្លួន និងការអនុវត្តច្បាប់ទាំងនៅកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ។

- រៀបចំជាការស្ទង់មតិតាមរយៈបញ្ជីសំណួរសំខាន់ៗ រួមទាំងការព្រួយបារម្ភផ្នែកខាងក្នុង និងការប្រឈមនានាពេលអនុវត្តសកម្មភាពនៅតាមគោលដៅអង្គការសមាគម ។
- សង្គមស៊ីវិលក៏បានសិក្សាស្រាវជ្រាវ និងពិនិត្យការវិភាគគតិយុត្តិចំពោះការប្រឈមនៃការអនុវត្តន៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។
- សង្គមស៊ីវិលបាននិងកំពុងប្រមូលចងក្រងករណីនានាលើបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។
- ក្រុមមេធាវីធ្វើការវិភាគលើមាត្រាមួយចំនួនដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងពីការបារម្ភ បញ្ហាប្រឈម និងអនុសាសន៍របស់គេ ។
- ធ្វើការបង្ហាញលទ្ធផល និងពិគ្រោះយោបល់ជាមួយសមាគម និងអង្គការដែលបានចូលរួមក្នុងដំណើរសិក្សា ។

៥. កម្រងធាតុចូលលើខ្លឹមសារនៃបទប្បញ្ញត្តិច្បាប់ស្នើសុំធ្វើវិសោធនកម្ម

អង្គការសង្គមស៊ីវិល ស្នើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លើមាត្រាមួយចំនួនដែលជះឥទ្ធិពលដល់លំហរសង្គមស៊ីវិល បរិយាកាសអំណោយផល និងលទ្ធិប្រជាធិបតេយ្យដូចខាងក្រោមៈ

| ល.រ | មាត្រា | បទប្បញ្ញត្តិដើម | សំណើសុំធ្វើវិសោធនកម្ម | មូលដ្ឋានគតិយុត្តិ/បញ្ហាប្រឈមក្នុងការអនុវត្តកន្លងមក |
|---|---|---|---|---|
| ១ | មាត្រា ១ | ច្បាប់នេះមានគោលបំណងធានាការការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួននិងការពារផលប្រយោជន៍សាធារណៈព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬ អង្គការមិនមែនរដ្ឋា-ភិបាលជាមួយអាជ្ញាធរសាធារណៈ ។ | ច្បាប់នេះមានគោលបំណងធានាការការពារសិទ្ធិសេរីភាពក្នុងការបង្កើត *បើក និងប្រតិបត្តិការរបស់* សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍សាធារណៈព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាង សមាគម និង/ឬ អង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ។ | សម្រួលពាក្យពេចន៍ឲ្យបានច្បាស់លាស់ដើម្បីឲ្យអនុលោមតាម **<u>មាត្រា ៤២</u>** នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលធានាសិទ្ធិបង្កើតសមាគម ។ |
| | មាត្រា ៧ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ | ១. ក្រសួងមហាផ្ទៃអាចតម្រូវឲ្យសាមីអង្គការដែលដាក់ពាក្យសុំធ្វើការកែតម្រូវអក្ខរាវិរុទ្ធបានតែមិនអាចតម្រូវឱ្យធ្វើ |

| | | | | |
|---|---|---|---|---|
| | | និងច្បាប់នានាជាធរមាន ហើយត្រូវចែងចំណុចសំខាន់ៗ ដូចខាងក្រោម៖<br>១. គោលបំណង និងគោលដៅ<br>២. ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ<br>៣.សញ្ញាសម្គាល់មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ឬស្ថាប័នអន្តរជាតិ<br>៤.វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ | និងច្បាប់នានាជាធរមាន ហើយត្រូវចែងចំណុចសំខាន់ៗ ដូចខាងក្រោម៖<br>១. គោលបំណង និងគោលដៅ<br>២. ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ<br>៣. សញ្ញាសម្គាល់មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ឬស្ថាប័នអន្តរជាតិ | ការកែតម្រូវពាក្យពេចន៍ដែលជាការចង់បានរបស់អ្នកដាក់ពាក្យសុំចុះបញ្ជីទេ ព្រោះអ្នកដាក់ពាក្យបានតម្រូវតាមលក្ខខណ្ឌមាត្រា៧ នេះគ្រប់ចំណុចទាំងអស់រួចហើយ។<br>២. គួរតែមានសេចក្តីណែនាំរួមមួយអំពីការដាក់ពាក្យ និងលក្ខខណ្ឌ ដែលពលរដ្ឋអាចរៀបចំ និងងាយស្រួល ហើយក្រសួងមហាផ្ទៃគួរធ្វើសវនាការបច្ចេកទេសជាមួយក្រុមដែលដាក់ពាក្យ ដើម្បីផ្តល់ឱកាសការពារនូវអ្វីដែលអ្នកដាក់ពាក្យបានសរសេរ ហើយក្រសួងមហាផ្ទៃអាចយល់បានថាចង់និយាយពីអ្វីៗ។ ការពិនិត្យ និងពិភាក្សា មាត្រា៧ ផ្តល់នូវលក្ខខណ្ឌសម្រាប់បង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីក្លាយជានីតិបុគ្គលស្របច្បាប់ ដោយតម្កល់ឯកសារនៅក្រសួងមហាផ្ទៃ។ ដោយឡែក លក្ខន្តិកៈក៏ត្រូវបានសរសេរតាមទម្រង់ដែលផ្តល់ដោយក្រសួងមហាផ្ទៃដែរ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងកន្លងមក លក្ខន្តិកៈរបស់សមាគមអង្គការ ដែលបានដាក់ពាក្យសុំចុះបញ្ជីទៅក្រសួងមហាផ្ទៃ ត្រូវបានមន្ត្រីទទួលបន្ទុកក្នុងក្រសួងតម្រូវឱ្យធ្វើការកែ |

| | | | | |
|---|---|---|---|---|
| | | ការផ្លាស់ប្តូរ<br>ការដកហូតតំណែង ប្រធាន<br>ឬតំណែងនាយកប្រតិបត្តិ<br>៥. វិធាននៃការប្តូរឈ្មោះ<br>ឬការប្តូរសញ្ញាសម្គាល់<br>ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ<br>៦.ប្រភពធនធាន និងទ្រព្យសម្បត្តិ<br>៧. វិធាននៃការគ្រប់គ្រងធនធាន<br>និងទ្រព្យសម្បត្តិ<br>៨. វិធាននៃការរំលាយ<br>វិធាននៃការចាត់ចែងធនធាន<br>និងទ្រព្យសម្បត្តិនៅពេលត្រូវ<br>បាន<br>រំលាយ។ | ៤. វិធាននៃការជ្រើសរើស<br>ការបញ្ឈប់ ការបណ្តេញចេញ<br>ការផ្លាស់ប្តូរ ការដកហូតតំណែង<br>ប្រធាន<br>ឬតំណែងនាយកប្រតិបត្តិ<br>៥. វិធាននៃការប្តូរឈ្មោះ<br>ឬការប្តូរសញ្ញាសម្គាល់<br>ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ<br>៦. ប្រភពធនធាន និងទ្រព្យសម្បត្តិ<br>៧. វិធាននៃការគ្រប់គ្រងធនធាន<br>និងទ្រព្យសម្បត្តិ<br>៨. វិធាននៃការរំលាយ<br>វិធាននៃការចាត់ចែងធនធាន<br>និងទ្រព្យសម្បត្តិនៅពេលត្រូវបា<br>ន<br>រំលាយ។ | តម្រូវទៅតាមការចង់បានរបស់មន្ត្រីក្រសួង<br>ដោយមិនបានគោរពនូវស្មារតីដើម<br>នៃក្រុមមនុស្សជាស្ថាបនិក<br>ដែលបានរៀបចំបង្កើតសមាគម អង្គការ នោះឡើយ។<br>ទោះបីពួកគេបានបំពេញតាមគ្រប់ចំណុចទាំងអស់ក្នុ<br>ងមាត្រា៧ នេះក៏ដោយ។ ផ្អែកតាមមាត្រានេះ<br>មានភាពទូលំទូលាយសមល្មមដែលអនុញ្ញាតឱ្យពល<br>រដ្ឋខ្មែរអាចដាក់គំនិត<br>យោបល់របស់ខ្លួនជាខ្លឹមសារនៃលក្ខខណ្ឌផ្ទៃក្នុង។ល<br>។ ដែលក្នុងនោះ ជាតំណាងឱ្យស្មារតី<br>និងក្តីស្រមៃរបស់ក្រុមពួកគេ<br>ជាពិសេសគឺក្រុមរបស់គេយល់ដូចគ្នាថា<br>ពាក្យនោះមានន័យយ៉ាងម៉េចសម្រាប់ការងាររបស់ក្រុ<br>មពួកគេ និងនីតិបុគ្គលដែលនឹងត្រូវបង្កើត។<br><br>ខ្លឹមសារនៃលក្ខន្តិកៈគឺជាស្មារតី<br>និងជាគំនិតឯករាជ្យនៃក្រុមមនុស្សជាស្ថាបនិក<br>ដែលបានរៀបចំបង្កើតសមាគម<br>និងអង្គការមិនមែនរដ្ឋាភិបាលនោះឡើង<br>ដោយគ្មានការជ្រៀតជ្រែកណាមួយពីអាជ្ញាធររដ្ឋ។ |

| | | | | |
|---|---|---|---|---|
| ៤ | មាត្រា ៨ | ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិតស្នើសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។<br><br>ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឲ្យធ្វើការចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្រសួងមហាផ្ទៃត្រូវសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតតម្រូវ។<br><br>ក្នុងករណីក្រសួងមហាផ្ទៃខកខានមិនបានសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី ២ ខាងលើ សមាគម ឬ | ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិតសុំរបស់សមាគម ឬ អង្គការមិនមែនរដ្ឋា-ភិបាលក្នុងស្រុកហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃនៃថ្ងៃធ្វើការ ។<br><br>ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើឲ្យធ្វើការចុះបញ្ជីស្តីពី *ចំណុចដែលត្រូវកែតម្រូវ* ក្នុងរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃនៃថ្ងៃធ្វើការ ។<br>*ក្នុងករណីដែលអ្នកស្នើសុំមិនយល់ស្របនឹងលក្ខខណ្ឌកែតម្រូវរបស់ក្រសួង អ្នកស្នើសុំត្រូវធ្វើលិខិតតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ។*<br>ក្រសួងមហាផ្ទៃត្រូវសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ ។ | **កថាខណ្ឌទី១៖** សមាគម និងអង្គការមួយចំនួនកន្លងមកបានជួបបញ្ហា ដែលសំណើសុំចុះបញ្ជីត្រូវបានមន្ត្រីក្រសួងមហាផ្ទៃតម្រូវឲ្យធ្វើការកែតម្រូវជាច្រើនដង ហើយម្តងមួយៗ គឺមានរយៈពេលយូរ បូកសរុបចូលគ្នា គឺលើស ៤៥ថ្ងៃ។ សមាគម អង្គការខ្លះ បានចំណាយពេលអស់ជាច្រើនខែ និងចុងក្រោយត្រូវកែតម្រូវតាមការចង់បានរបស់មន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបានចុះបញ្ជី ឬទទួលស្គាល់។<br><br>**កថាខណ្ឌទី២៖** ការអនុវត្តន៍កថាខណ្ឌទី២ នៃមាត្រា៨ នេះ គឺអនុវត្តមិនបានត្រឹមត្រូវ ព្រោះអ្នកដាក់ពាក្យចុះបញ្ជីត្រូវបានមន្ត្រីទទួលបន្ទុកការចុះបញ្ជីតម្រូវឱ្យកែជាច្រើនលើកច្រើនសារនោះ លើសពីរយៈពេលកំណត់ ៤៥ ថ្ងៃ ហើយត្រូវបានអូសបន្លាយជាច្រើនខែផងដែរ។ កន្លងមក អ្នកដាក់ពាក្យសុំចុះបញ្ជីសមាគម និងអង្គការ មិនដែលបានជួបមុខមន្ត្រីដើម្បីធ្វើការបំភ្លឺតវ៉ាពីជំហររបស់ខ្លួនម្តងណាទេ ក៏ប៉ុន្តែគ្រាន់តែបានទទួលដំណឹងឲ្យធ្វើការកែចំណុចនេះ ឬចំណុចនោះ ហើយត្រូវរង់ចាំបន្តទៅទៀត។ ជាបទពិសោធន៍កន្លងមកអង្គការសមាគមមួយចំនួនមិនបានទទួលសេចក្តីជូនដំណឹង |

| | | | | |
|---|---|---|---|---|
| | | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវចាត់ទុកថា បានទទួលការចុះបញ្ជីស្របតាមច្បាប់នេះ។ ក្នុងករណីនេះ ក្រសួងមហាផ្ទៃត្រូវធ្វើនិយតកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ។<br><br>ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគ ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលរកឃើញថា មានគោលបំណង និងទិសដៅដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។ | រយៈពេលនៃការចុះបញ្ជីសរុបមិនលើសពី ៦០ថ្ងៃនៃថ្ងៃធ្វើការឡើយ ចំពោះករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការកែតម្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃច្បាប់នេះរួចហើយ។<br><br>ក្នុងករណីដែលក្រសួងមហាផ្ទៃខកខានមិនបានសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌ ១ និងកថាខណ្ឌ ២ ខាងលើ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវចាត់ទុកថាបានទទួលការចុះបញ្ជីស្របតាមច្បាប់នេះ ។ ក្នុងករណីនេះក្រសួងមហាផ្ទៃត្រូវធ្វើនិយតកម្មឯកសារចុះបញ្ជីផ្តល់ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ។<br><br>~~*ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម*~~ | ឬការណែនាំផ្សេងៗជាលាយលក្ខណ៍អក្សរទេ ។ គួរតែមានការបើកឱកាសឲ្យអ្នកដាក់ពាក្យសុំបានការពារជំហររបស់ខ្លួន នៅចំពោះមុខគណៈកម្មការ ដែលធ្វើឲ្យអ្នកដាក់ពាក្យទុកចិត្តថា គណៈកម្មការបានវិនិច្ឆ័យដោយឥតលម្អៀង។ វិវាទនៃការចុះបញ្ជីនេះ ត្រូវបានផ្តល់អាណត្តិឲ្យក្រសួងមហាផ្ទៃ ជាអ្នកសម្រេចភាគច្រើន ចំណែកពលរដ្ឋដែលជាអ្នកស្នើសុំបង្កើត ចុះបញ្ជី មិនមានឱកាសតវ៉ាតទល់នៅថ្នាក់រដ្ឋបាល។ ម៉្យាងវិញទៀត ប្រសិនប្តឹងទៅតុលាការតាមលំដាប់ថ្នាក់ នឹងត្រូវចំណាយពេលវេលាយូរ ព្រោះនីតិវិធីតុលាការមានច្រើនថ្នាក់ទើបសម្រេចបាន ទោះជារឿងរដ្ឋបាលក៏ដោយ ។<br><br><u>កថាខណ្ឌទី៤ ៖</u><br>កថាខណ្ឌនេះមិនតម្រូវឲ្យក្រសួងមហាផ្ទៃផ្តល់នូវមូលហេតុក្នុងការបដិសេធការចុះបញ្ជីដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទេ។ មូលហេតុប្រើជាយុត្តិកម្មសម្រាប់បដិសេធការចុះបញ្ជីនេះបានធ្វើហួសការកំណត់នៅក្នុង កតិកាសញ្ញា |

| | | | | |
|---|---|---|---|---|
| | | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងទៅតុលាការ។ | ~~*ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថាមានគោលបំណងនិងទិសដៅដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។*~~<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជីមានសិទ្ធិ *ប្តឹងទៅសាលាឧទ្ធរណ៍*។ | ICCPR មាត្រា ២២ ក.២ ដែលរឹតត្បិតតែក្នុងករណីចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យជាផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពអ្នកដទៃ ។<br><br>វាក្យស័ព្ទទាំងអស់នេះ មានលក្ខណៈទូលំទូលាយខ្លាំងពេក និងបង្កប់នូវភាពមិនច្បាស់លាស់សម្រាប់ការបកស្រាយផ្លូវច្បាប់ ។ ខ្លឹមសារនៃវាក្យស័ព្ទដែលមានភាពមិនច្បាស់លាស់បែបនេះអនុញ្ញាតអោយស្ថាប័នមានសមត្ថកិច្ចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបកស្រាយច្បាប់ និងសម្រេចបដិសេធការចុះបញ្ជីដែលស្នើឡើងដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងករណីនេះតើក្រសួងមហាផ្ទៃ អាចដឹងថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះប៉ះពាល់ដល់សណ្តាប់ធ្នាប់ សន្តិសុខសង្គម ឬការណ៍ដទៃទៀតដោយវិធីយ៉ាងដូចម្តេច បើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះមិនទាន់បានចុះបញ្ជីផង ?។ បើកថាខណ្ឌនេះមិនត្រូវបានដកចេញ |

| | | | | |
|---|---|---|---|---|
| | | | | វាជាការបង្កភាពងាយស្រួលដល់មន្ត្រីឬស្ថាប័នដែលទទួលបន្ទុកចុះបញ្ជីបកស្រាយតាមកាលៈទេសៈ ឬតាមស្ថានភាពនៃការវិវត្តន៍ខាងនយោបាយក្នុងការបដិសេធការចុះបញ្ជី។<br><br>អ្វីដែលសំខាន់គឺកថាខណ្ឌទី៤នេះគឺមិនផ្ទុះបញ្ច្រាំងពីខ្លឹមសារនៃមាត្រា៥, ៦ និង៧នៃច្បាប់នេះឡើយ។ ព្រោះថាបើអ្នកស្នើសុំចុះបញ្ជីបានបំពេញតាមលក្ខខណ្ឌតម្រូវនៃមាត្រា៥, ៦ និង៧រួចហើយក្រសួងមិនគួរយកមូលហេតុផ្សេងមកបដិសេធការចុះបញ្ជីសមាគឬអង្គការមិនមែនរដ្ឋាភិបាលនោះទេ។<br><br>កថាខណ្ឌទី៥៖ ដោយសារសកម្មភាពទាំងអស់នេះអាចជាប់ពាក់ព័ន្ធជាប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ដូច្នេះខ្លឹមសារនៃច្បាប់ ត្រូវកំណត់អោយបានច្បាស់លាស់អំពីសកម្មភាពនៃបទល្មើស ក្នុងគោលបំណង ដើម្បីកំណត់អំពីសង្គតិភាពនៃការបកស្រាយច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច។ ការចែងមិនច្បាស់លាស់ (ambiguous) បែបនេះ វានឹងក្លាយជាឧបករណ៍ដែលអនុញ្ញាតឲ្យអ្នកអនុវត្តច្បាប់អាចធ្វើការបកស្រាយបានតាមចិត្ត ដោយការប្រើសេរីភាពនៃឆន្ទានុសិទ្ធិផ្ទាល់ខ្លួនរបស់ម |

| | | | | |
|---|---|---|---|---|
| | | | | ន្ត្រីអនុវត្តច្បាប់ហើយនិងមានហានិភ័យធ្ងន់ធ្ងរសម្រាប់ការអនុវត្តន៍ច្បាប់។ |
| ៥ | មាត្រា ៩ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គល ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃ បានចុះបញ្ជី។ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជី សមាគម និង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនេះ ទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គល *និងអាចធ្វើសកម្មភាពរបស់ខ្លួនដោយសេរី ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងដល់អាជ្ញាធរសាធារណៈ*ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី ។ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនេះទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ។<br><br>~~*សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតិឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។*~~ | កថាខណ្ឌទី១ នៃមាត្រានេះ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ប៉ុន្តែនៅពេលអនុវត្តសកម្មភាពកន្លងមក សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអាជ្ញាធរតម្រូវឱ្យដាក់លិខិតសុំការអនុញ្ញាត (មុនសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃលេខ ២០០៦ សជណ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ចេញដោយក្រសួងមហាផ្ទៃ) ព្រមទាំងជូននូវសេចក្តីសម្រេចអំពីការចុះបញ្ជីរបស់ខ្លួន។<br><br>កថាខណ្ឌទី២ នៃមាត្រា៩ មិនបានលើកទឹកចិត្តឱ្យពលរដ្ឋ ឬអង្គការក្នុងស្រុកចូលរួមក្នុងកិច្ចការសង្គមដោយសកម្ម និងរស់រវើកនោះឡើយ ហើយឥទ្ធិពលនៃកថាខណ្ឌនេះ ខុសពីគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសង្គម។ |

| | | | | |
|---|---|---|---|---|
| | | | | កថាខណ្ឌនេះថែមទាំងមិនបានកំណត់ឲ្យច្បាស់លាស់ពីលក្ខណៈវិនិច្ឆ័យអប្បបរិមា ដូចជាផ្អែកលើទំហំថវិកាគម្រោង និរន្តរភាពនៃការប្រតិបត្តិការ (ផ្អែកលើភាពអចិន្ត្រៃយ៍ ឬមិនចិន្ត្រៃយ៍នៃប្រតិបត្តិការគម្រោង) ជាដើម នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការចុះបញ្ជីជានីតិបុគ្គលមួយ។ |
| ៦ | មាត្រា ១០ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃចុះបញ្ជី ។<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន | ~~សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃចុះបញ្ជី ។~~<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ | **កថាខណ្ឌទី១៖**<br>ក្រោយពីបានក្លាយជានីតិបុគ្គលដែលមាននាមករណ៍ មានអាសយដ្ឋាន មានរចនាសម្ព័ន្ធដឹកនាំនិងអនុវត្ត មានធនធាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិស្វ័យភាពក្នុងការដឹកនាំ គ្រប់គ្រង សម្រេចចិត្ត ក្នុងការអនុវត្តន៍ ឬមិនអនុវត្តក្នុងក្របខណ្ឌលក្ខន្តិកៈ និងច្បាប់ជាធរមាន ក្នុងឋានៈជានីតិបុគ្គលឯករាជ្យ មិនរកប្រាក់ចំណេញ និងមានសិទ្ធិជានីតិបុគ្គល ដែលគោលការណ៍ទាំងនេះមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ ក្នុងន័យនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ជារបស់ឯកជនដែរ រួមទាំងពត៌មានឯកជនរបស់នីតិបុគ្គល ដែលក្នុងនោះមានរាល់ព័ត៌មានគណនីធនាគាររបស់ខ្លួន។ មាត្រា ១០ កថាខណ្ឌទី១ បានដាក់កាតព្វកិច្ចដល់ |

| | | | | |
|---|---|---|---|---|
| | | ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃគិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួលដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដែលបានផ្លាស់ប្តូរ ។ | ឬក្នុងរយៈពេលយ៉ាងយូរ ៩០ ថ្ងៃគិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬ ប្រែប្រួលដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។ ការផ្លាស់ប្តូរទីស្នាក់ការត្រូវជូនដំណឹងទៅសាលាឃុំ សង្កាត់ចាស់ និងសាលាឃុំ សង្កាត់ថ្មីដែលសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទៅតាំងទីស្នាក់ការថ្មី ក្នុងរយៈពេលមិនហួសពី៩០ថ្ងៃបន្ទាប់ពីបានផ្លាស់ប្តូរ ។ សាលាឃុំ សង្កាត់ត្រូវចេញទម្រង់នៃការទទួល ដោយបោះត្រាឃុំ សង្កាត់ជាតឹកតាងបញ្ជាក់។ | សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឲ្យបើកចំហនូវរាល់ព័ត៌មានគណនីធនាគារ ដោយមិនឆ្លុះបង្ហាញពីឆន្ទៈ របស់ម្ចាស់គណនីនោះទេ ។ តាមការពិភាក្សាជាមួយមន្ត្រីសមាគម អង្គការនានា គេមានការបារម្ភអំពីការផ្ញើព័ត៌មានធនាគារ តាមមាត្រានេះ ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បង្ហាញថា មាត្រា១០ ដែលដាក់កាតព្វកិច្ចតម្រូវឱ្យសមាគម និងអង្គការជូនដំណឹងរាល់ព័ត៌មានគណនីធនាគារ ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើឲ្យមានក្តីបារម្ភយ៉ាងខ្លាំង ហើយយល់ថាគឺជាការរំលោភសិទ្ធិឯកជនរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការគ្រប់គ្រងធនធានរបស់ខ្លួន។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ មានតែចៅក្រមស៊ើបសួរទេដែលមានតួនាទីក្នុងការបង្គាប់ឲ្យធនាគារបើកចំហរ និងត្រួតពិនិត្យគណនីធនាគារបុគ្គលណាមួយដែលត្រូវបានតុលាការសង្ស័យឈានទៅដល់ការស៊ើបអង្កេត ។<br><br>តាមច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការសងប្រាក់ ដែលចូលជាធរមានក្នុងឆ្នាំ |

| | | | | |
|---|---|---|---|---|
| | | | | ២០០៥ ចែងពន្យល់ពាក្យ គណនី ថា «១៣-គណនី សំដៅដល់គណនីទាំងឡាយ ដែលបានបើកនៅក្រោមកិច្ចសន្យារវាងអតិថិជន និងធនាគារ ទោះបីជាគណនីចរន្ត គណនីផ្ញើរប្រាក់ ឬគណនីផ្សេងទៀតក្តី រួមទាំងគណនីនៅក្រោមទំនាក់ទំនងពិសេស ដែលបង្កើតឡើងក្នុងគោលបំណងអនុវត្តប្រតិវត្តិការទូទាត់សងប្រាក់តែមួយប៉ុណ្ណោះ។» នៅក្នុងប្រតិបត្តិការក្រោមច្បាប់នេះ គណនី គឺជាប្រតិបត្តិការក្រោមកិច្ចសន្យារវាងធនាគារ និងអតិថិជន ប៉ុណ្ណោះ។ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនមែនជាភាគីក្នុងកិច្ចសន្យា បើកគណនីទេ។ ជាមួយគ្នានេះក្រមរដ្ឋប្បវេណីក៏បានចែងអំពីគោលការណ៍រួមនៃសិទ្ធិរបស់នីតិបុគ្គល។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល គឺជានីតិបុគ្គលមិនរកប្រាក់ចំណេញដែលមានរាល់សិទ្ធិ ករណីយកិច្ច និងកាតព្វកិច្ចដូចបុគ្គលឯទៀតដែរ រួមទាំងសិទ្ធិមានទ្រព្យសម្បត្តិឯកជន និងស្វ័យភាពបុគ្គលក្នុងការគ្រប់គ្រង (ស្វ័យអភិបាលកិច្ច) ជានីតិបុគ្គលឯករាជ្យអព្យាក្រឹត្យ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល |

| | | | | |
|---|---|---|---|---|
| | | | | មិនគួរស្ថិតក្រោមស្ថានភាពជាប់សង្ស័យពីបទល្មើសអ្វីឡើយ ក៏ប៉ុន្តែនីតិបុគ្គលនេះស្ថិតក្រោមការការពារនៃគោលការណ៍រដ្ឋធម្មនុញ្ញ មាត្រា ៣៨ ដែលចាត់ទុកថាគ្មានទោសដរាបណាមិនទាន់មានសាលក្រមស្ថាពរ។ មាត្រា ២១៩ ដល់ ២២៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការសងប្រាក់ បានថែងពន្យល់អំពីលក្ខខណ្ឌ សិទ្ធិ និងកាតព្វកិច្ចរវាងធនាគារ និងអតិថជនដែលជាម្ចាស់គណនីក្នុងធនាគារ ។ ជារួម រាល់ព័ត៌មានពាក់ព័ន្ធនឹងគណនីធនាគារ គឺជាព័ត៌មានឯកជនដែលក្នុងន័យនេះ មាត្រា ១០ បានដាក់កាតព្វកិច្ចតម្រូវឱ្យបើកចំហរព័ត៌មានឯកជនទៅក្រសួងរបស់រដ្ឋ ដែលអតិថិជនមិនពេញចិត្តនឹងបើកចំហ។ ជារួម ក្រសួងរបស់រដ្ឋ ក៏ចូលរួមធានានូវសិទ្ធិឯកជនភាព និងស្វ័យភាពរបស់បុគ្គលឯកជន ពិសេសទ្រព្យសម្បត្តិឯកជន (រាល់ព័ត៌មានអំពីគណនីធនាគារដែរ)។ <br>**កថាខណ្ឌទី២៖** សមាគម និងអង្គការយល់ថាការជូនដំណឹងទៅក្រសួងមហាផ្ទៃពីការផ្លាស់ប្តូរលក្ខន្តិកៈ ទីស្នាក់ការ និងនាយកប្រតិបត្តិ |

| | | | | |
|---|---|---|---|---|
| | | | | ជាការសមស្របអាចអនុវត្តបាន មិនប៉ះពាល់ឯកជនភាព និងឯករាជ្យភាពនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទេ ។ ប៉ុន្តែ ការជូនដំណឹងអំពីការផ្លាស់ប្តូរទាំងនេះ មិនមែនជាមូលហេតុនៃការទទួលបានសុពលភាព នោះឡើយ។ ការជូនដំណឹងនេះ គ្រាន់តែឱ្យក្រសួង ស្ថាប័ននានាបានដឹងអំពីការផ្លាស់ប្តូរ និងដើម្បីធ្វើទំនាក់ទំនងប៉ុណ្ណោះ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែង ការផ្លាស់ប្តូរនាយក ឬនាយិកាប្រតិបត្តិ ឬប្រធាន ក្រសួងមហាផ្ទៃតម្រូវឱ្យមានការទទួលស្គាល់ដោយចេញលិខិតថ្មីមួយទៀតនិងមានឈ្មោះអ្នកថ្មី។ ការតម្រូវនេះ ហួសពីការជូនដំណឹង ដែលកថាខណ្ឌទី២ នៃមាត្រា១០នេះតម្រូវ។ បន្ថែមទៀត ការបើកគណនីធនាគារក៏មិនគួរទាល់តែមានលិខិតទទួលស្គាល់ពីការជូនដំណឹងរបស់សមាគម ឬអង្គការដែលបានជូនដំណឹងទៅក្រសួងមហាផ្ទៃទើបអាចប្រើប្រាស់ជាតឹកតាងបាននោះទេ។ គួរតែមានត្រឹមការវាយត្រាចូលចាត់ទុកថាជាការគ្រប់គ្រាន់ក្នុងដំណើរការចុះបញ្ជីពន្ធដារ ឬបើកគណនីធនាគារបាន។ |

| | | | | |
|---|---|---|---|---|
| | | | | ជាក់ស្តែង<br>ការជូនដំណឹងដែលមានវាយត្រាចូលគួរចាត់ទុកថាបានបំពេញត្រឹមត្រូវតាមច្បាប់កំណត់<br>ដែលអាចយកទៅបញ្ជាក់ក្នុងការចុះបញ្ជីបង់ពន្ធ ឬស្នើសុំបើកគណនីធនាគារផ្សេងៗបាន។ សមាគម និងអង្គការបានចុះបញ្ជីក្លាយជានីតិបុគ្គលស្របច្បាប់រួចហើយ ហេតុនេះ<br>ការតម្រូវឱ្យមានលិខិតចេញទទួលស្គាល់នាយក ឬនាយិកា ឬប្រធានថ្មី ជាការលំបាកទាំងសមាគម អង្គការ និងទាំងស្ថាប័នផ្សេងទៀត<br>រួមទាំងធនាគារផង<br>ព្រោះក្នុងមាត្រាច្បាប់បានចែងត្រឹមជាការជូនដំណឹងមិនមែនតម្រូវឱ្យស្នើសុំទទួលស្គាល់នោះទេ។<br><br>ដោយឡែកការស្នើសុំឱ្យធ្វើវិសោធនកម្មពីការជូនដំណឹងទៅក្រសួងមហាផ្ទៃពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការពីក្រសួងទៅឃុំ<br>សង្កាត់វិញដោយសារមូលហេតុ៣គឺ៖<br>ទី១. ឃុំ<br>សង្កាត់ជារដ្ឋបាលថ្នាក់ក្រោមរបស់ក្រសួងមហាផ្ទៃ ហើយក្រសួងបានពង្រឹងសមត្ថភាពរបស់ពួកជាច្រើនឆ្នាំកន្លងមកហើយ |

| | | | | |
|---|---|---|---|---|
| | | | | ដូចនេះពួកគេគួរតែអាចទទួលខុសត្រូវបានក្នុងការបន្ដរាយការជូនក្រសួងមហាផ្ទៃ។<br>ទី២.<br>ជាការបង្ហាញពីប្រសិទ្ធភាពនៃទំនាក់ទំនងរវាងអាជ្ញាធរថ្នាក់ក្រោមជាតិ និងក្រសួងមហាផ្ទៃផងដែរ។<br>ទី៣.អង្គការនៅតាមបណ្ដាខេត្តមានការពិបាកក្នុងការធ្វើដំណើរមកភ្នំពេញ ហើយត្រូវចំណាយថវិកា និងពេលវេលាគ្រាន់តែការជូនដំណឹងមកក្រសួងមហាផ្ទៃពីការប្ដូរទីតាំងទីស្នាក់ការ។ |
| ៧ | មាត្រា ១១ | លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលនិងសម្រាប់ជនបរទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br><br>លក្ខខណ្ឌ<br>បែបបទនិងនីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសមាគមសម្រាប់អនីតិជន<br>ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ | ~~*លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលនិងសម្រាប់ជនបរទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។*~~<br><br>លក្ខខណ្ឌ បែបបទនិងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគមសម្រាប់អនីតិជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ | មាត្រានេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិច្ចសហការរវាងនីតិបុគ្គលជាសមាគមឬអង្គការក្នុងការអនុវត្តសកម្មភាពសំខាន់ៗរួមគ្នាដូចជាកិច្ចការបោះឆ្នោត ការតស៊ូមតិ អំពីច្បាប់នានា<br>ដែលមានច្បាប់ស្ដីពីសមាគម<br>និងអង្គការមិនមែនរដ្ឋាភិបាលជាដើម។<br>ក្រុមការងារចំពោះកិច្ច ឬហៅថា (Adhoc Working Group) ដែលត្រូវបាន បង្កើតឡើង<br>គឺត្រូវបានរាំងមិន<br>អោយធ្វើសកម្មភាពដោយមាត្រានេះ<br>ជាក់ស្ដែងបន្ទប់ស្ថានការណ៍សម្រាប់សង្កេតការណ៍<br>បោះឆ្នោត<br>ដែលសម្របសម្រួលដោយអង្គការខុមហ្វ្រែល |

| | | | | |
|---|---|---|---|---|
| | | | | ត្រូវបានក្រសួងមហាផ្ទៃចេញលិខិតបទបន្ទាប់ពីការបោះឆ្នោតក្នុងឆ្នាំ២០១៧ រួច។<br><br>ករណី បណ្តាញនៃអង្គការ សមាគម ដែលត្រូវបានបង្កើតឡើងនៅក្នុងខេត្តក៏ទទួលរងការរាំងមិនអោយធ្វើសកម្មភាពការងារ និងមិនទទួលបានការ សហការពីអាជ្ញាធរមានសមត្ថកិច្ច ដូចគ្នា។ ជាការអនុវត្តកន្លងមក នៅតាមខេត្តមួយចំនួនដូចជាខេត្តស្វាយរៀង ជាដើម ក្រុមអាជ្ញាធរ មានសមត្ថកិច្ច តែងសួរនាំអំពីការចុះបញ្ជីរបស់ ក្រុមបណ្តាញអង្គការ សមាគម ដែលត្រូវបានចងក្រងបង្កើតឡើងជាក្រុមការងារចំពោះកិច្ច ជាបណ្តាញអន្តរវិស័យធ្វើការដើម្បីជួយគ្នាទៅវិញទៅមក។ ការតម្រូវអោយក្រុមការងារចំពោះកិច្ចនៃអង្គការសង្គមស៊ីវិល ចុះបញ្ជីជានីតិបុគ្គល គឺជាការបង្កើតបន្ទុកបន្ថែមទៀត ដោយសារមូលហេតុថា នីតិបុគ្គលមួយដែលបានបង្កើតឡើង ត្រូវមានកាតព្វកិច្ចផ្លូវច្បាប់ពាក់ព័ន្ធនានា ពិសេសច្បាប់ ឬបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ពួកគេ។ |

| | | | | |
|---|---|---|---|---|
| | | | | ក្រុមការងារចំពោះកិច្ច (Adhoc Working Group) ដែលត្រូវបានបង្កើតឡើងដោយក្រុមនីតិបុគ្គល ឬឬវន្តបុគ្គល គប្បីទទួលបាននូវសិទ្ធិសេរីភាពពេញលេញ និងទូលំទូលាយ ដើម្បីធ្វើការងារអ្វីមួយរួមគ្នា និងធ្វើជាតំណាងស្របច្បាប់ ចំពោះការកសាងភាពជាដៃគូជាមួយអាជ្ញាធរមានសមត្ថកិច្ច (ក្រសួង ឬស្ថាប័នរដ្ឋពាក់ព័ន្ធនានា) ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាប្រឈមរួម។ |
| ៨ | មាត្រា ២០ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬអនុស្សរណៈ ត្រូវស្ថិតនៅក្រោមនីតិរួមនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី ឬអនុស្សរណៈ *ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដែលមាន គោលដៅមនុស្សធម៌ ផ្តល់សេវាកម្មសង្គម សេដ្ឋកិច្ច លើកម្ពស់សិទ្ធិ និងលទ្ធិប្រជាធិបតេយ្យសុទ្ធសាធ និងសកម្មភាពផ្សេងៗ ដើម្បីប្រយោជន៍សាធារណៈ ត្រូវទទួលបានការលើកទឹកចិត្ត និងអនុគ្រោះផ្នែកសារពើពន្ធនានាដោយស្វ័យប្រវត្តិ។* | អង្គការ សមាគមដែលបង្កើតឡើងគ្មានគោលបំណងរកកម្រៃទេ គឺធ្វើការដើម្បីផលប្រយោជន៍។ តាមគោលបំណងរបស់ច្បាប់នេះ មានការលើកទឹកចិត្ត និងការពារសិទ្ធិសេរីភាពពលរដ្ឋខ្មែរ ក្នុងការចូលរួមសកម្មក្នុងកិច្ចការសង្គម។ ហេតុដូចនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល គួរតែទទួលបាននូវការលើកទឹកចិត្ត និងការអនុគ្រោះដោយឡែកចំពោះធនធានដែលរកបាន និងធនធានសម្រាប់ដំណើរការរបស់នីតិបុគ្គលមិនរកផលចំណេញ។ ការអនុវត្តិទូទៅដោយគ្មានការលើកលែងចំពោះសកម្ម |

| | | | | |
|---|---|---|---|---|
| | | | | ភាពដែលចំណាយសម្រាប់សង្គម និងមិនរកផលចំណេញ បានបណ្ដាលឲ្យមានការពិបាកដល់ម្ចាស់មូលនិធិដែលមានចិត្តសប្បុរស បរិច្ចាគសម្រាប់កិច្ចការសង្គម។ នៅប្រទេសខ្លះ ប្រាក់ដែលគេបរិច្ចាគសម្រាប់មនុស្សធម៌ សង្គមស៊ីវិលត្រូវបានរួចពីកាតព្វកិច្ចពន្ធ ហើយជាបន្ទុករបស់រដ្ឋ។ មិនតែប៉ុណ្ណោះការបំពេញឯកសារពន្ធយ៉ាងស្មុគស្មាញដែលជាបន្ទុកចំពោះបុគ្គលិកគណនេយ្យនៅក្នុងអង្គការនីមួយៗ ដែលត្រូវធ្វើការទ្វេដង។ សមាគមនិងអង្គការសង្គមស៊ីវិលមួយចំនួនគ្មានសមត្ថភាពបំពេញតាមលក្ខខណ្ឌពន្ធដារបាន ហើយឯកសារដែលត្រូវបំពេញមានច្រើននិងស្មុគស្មាញពិបាកយល់ ជាពិសេសអង្គការយុវជន និងសមាគម ឬអង្គការនៅតាមបណ្ដាខេត្តមួយចំនួន។ |
| ៩ | មាត្រា ២៤ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។ | ~~អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត្យចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ។~~ | អព្យាក្រឹត្យភាពក្នុងមាត្រានេះ មានន័យទូលំទូលាយ។ ជាឧទាហរណ៍ តើសមាគម (បរទេស) និងអង្គការមិនមែនរដ្ឋាភិបាល ជួបនិយាយគ្នាជាមួយសមាជិកគណបក្សណាមួយ ទទួលទានអាហារជាមួយគ្នា ជួបប្រជុំជាមួយគ្នា ចូលជាសមាជិកបក្ស ឬផ្ដល់ហិរញ្ញប្បទាន។ល។ |

| | | | | |
|---|---|---|---|---|
| | | | | សេរីភាពក្នុងការប្រកាន់គំនិត មតិ យោបល់ និងជំហរផ្ទាល់ខ្លួន គឺជាសិទ្ធិសេរីភាពជាមូលដ្ឋានដែលធានាដោយរដ្ឋធម្មនុញ្ញ និងសេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ដែលរដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់។ មាត្រា ២៤ ក្នុងច្បាប់នេះបានបង្គាប់បញ្ជាឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវប្រកាន់ជំហរអព្យាក្រឹត ដែលបានបិទសិទ្ធិសេរីភាពក្នុងការសម្តែងមតិ មានចែងក្នុងគោលការណ៍សិទ្ធិមនុស្ស រដ្ឋធម្មនុញ្ញ និង ច្បាប់។<br><br>មាត្រា ២៤ បានចែងយ៉ាងទូលាយ មិនបានកំណត់និយមន័យឱ្យច្បាស់ អំពីសកម្មភាពដែលនាំដល់ការបាត់បង់អព្យាក្រឹតភាពរបស់អង្គការនោះទេ។ ភាពទូលំទូលាយនៃពាក្យជំហរអព្យាក្រឹតនេះ អាចនាំផលវិបាកដល់តួនាទីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ជាពិសេសកន្លងមកមានការលើកឡើងរបស់មន្ត្រីរដ្ឋថា អង្គការនេះបាត់បង់អព្យាក្រឹតភាព ឬមិនឯករាជ្យ ធ្វើឲ្យសាធារណៈជនមានការយល់ច្រឡំថា សមាគម ឬអង្គការមិនមែនរដ្ឋភិបាល អនុវត្តខុសច្បាប់ |

| | | | | |
|---|---|---|---|---|
| | | | | ដូចដែលមានចែងក្នុងមាត្រា ២៤ ដែលនាំសមាគម ឬអង្គការនោះនឹងត្រូវរំលាយតាមមាត្រា ៣០។ ឧទាហរណ៍ជាក់ស្តែង សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានចោទប្រកាន់ថាមិនអព្យាក្រិតខាងនយោបាយត្រូវបានរដ្ឋាភិបាលដាក់ឈ្មោះពួកគេក្នុងសៀវភៅស ដែលបោះចែកចាយយ៉ាងទូលំទូលាយ។ សមាគម អង្គការមិនមែនរដ្ឋាភិបាលបារម្ភថាអាជ្ញាធរនឹងបកស្រាយមាត្រានេះតាមស្ថានភាពនយោបាយក្តៅ ឬត្រជាក់។ ឧទាហរណ៍ថាសកម្មភាពដូចគ្នាប៉ុន្តែក្នុងស្ថានភាពនយោបាយធម្មតាគឺគ្មានបញ្ហា តែសកម្មនេះបើអនុវត្តម្តងទៀតដោយអង្គការក្នុងស្ថានភាពនយោបាយតានតឹងបែរជាត្រូវចាប់ពិរុទ្ធ ឬប្រឈម នឹងការផ្អាកសកម្មភាព ឬរំលាយចោលទៅវិញ។ |
| ១០ | មាត្រា ២៥ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវផ្ញើរទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ | ~~អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់ ។ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញ~~ | ចំពោះមាត្រា២៥ ចែងអំពីកាតព្វកិច្ចតម្រូវដាច់ខាតឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលផ្ញើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាច្បាប់ចម្លងពីច្បាប់ដើមដែលផ្ញើទៅម្ចាស់ជំនួយ។ល ។ |

| | | | | |
|---|---|---|---|---|
| | | មិនឱ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។<br>ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើម ដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានយឯកភាពយល់ព្រម។<br>របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥(ប្រាំ) ឆ្នាំ។ | ~~*ត្ថុពីម្ចាស់ជំនួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារ គម្រោងកម្មវិធី និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ ច្បាប់ដែលម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥ ឆ្នាំ ។*~~<br><br>ក្នុងករណី*មានបណ្ដឹងទៅ*~~ចាំបាច់~~ក្រសួងមហាផ្ទៃ *ឬ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាមី* អាចស្នើសុំរបាយការណ៍ស្ដីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ*ពាក់ព័ន្ធនឹងបណ្ដឹង*~~ប្រចាំឆ្នាំ~~របស់សមាគម *ឬអង្គការមិនមែនរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែ* | ការអនុវត្តន៍ភាគច្រើនមិនពេញចិត្តនឹងការបំពេញកាតព្វកិច្ចនេះទេ។ មូលហេតុដែលបានរកឃើញគឺពេលវេលារដ្ឋបាល ឬបុគ្គលិកត្រូវចំណាយច្រើនជាងមុន ហើយមានពេលវេលាកំណត់មិនឱ្យហួសពីថ្ងៃ២៨ ខែកុម្ភៈ ថែមទៀត។ ការដាក់កាតព្វកិច្ច ក្នុងមាត្រា ២៥ នេះ បានបន្ថែមបន្ទុកដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ជាជាងការសម្របសម្រួល និងការលើកទឹកចិត្តដល់ពលរដ្ឋឱ្យចូលរួមសកម្មភាពក្នុងកិច្ចការសង្គម តាមរយៈការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល សូម្បីតែរបាយការណ៍ទៅម្ចាស់ជំនួយខ្លះ ក៏អាចសុំពន្យារពេល ឬយឺតបានខ្លះដែរ។<br><br>ចំពោះទំនាក់ទំនងគតិយុត្ត រវាងនីតិបុគ្គលពីរមានក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស ជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក៏មិនឃើញមានកាតព្វកិច្ចទៅវិញទៅមកដែលបានព្រមព្រៀងគ្នាក្រោយពេលបង្កើតឡើយ។ ក្នុងករណីមួយចំនួនសមាគម ឬអង្គការបានចុះកិច្ចព្រមព្រៀង |

| | | | | |
|---|---|---|---|---|
| | | ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម។<br>អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើរទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើរទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និង កិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ | *លមានសាខា ឬការិយាល័យនៅប្រទេសកម្ពុជាដើម្បីជាព័ត៌មាន និងពិភាក្សារកដំណោះស្រាយថ្នាក់រដ្ឋបាល ។*<br>~~*អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ច្បាប់ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។*~~ | ឬអនុសារណៈយោគយល់ជាមួយក្រសួងនោះគូភាគីបានសម្តែងឆន្ទៈថា នឹងធ្វើរបាយការណ៍ជូន ឬត្រូវធ្វើអ្វីមួយតាមកាតព្វកិច្ចដែលបានព្រមព្រៀងគ្នា ក៏ប៉ុន្តែប្រសិនបើសមាគម ឬអង្គការមិនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងរបស់រដ្ឋទេនោះ មិនគួរជាប់កាតព្វកិច្ចបែបនេះឡើយ។ ជាមួយគ្នានេះដែរ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល តែងចុះកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ហើយម្ចាស់ជំនួយរបស់សមាគម ឬអង្គការក៏បានចុះកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់ លើកម្មវិធីជំនួយគ្មានសំណងរបស់គេជាមួយស្ថាប័នរដ្ឋួចហើយ ដែរ។<br><br>កាតព្វកិច្ចរបាយការណ៍ក្នុងមាត្រា ២៥ បានធ្វើឱ្យនីតិបុគ្គលជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្លាយជាការបង្ខិតបង្ខំ និងមានចម្ងល់ថា តើក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យករបាយការណ៍ទៅធ្វើអ្វី? តើក្រសួងរបស់រដ្ឋមានកាតព្វកិច្ចអ្វីជាមួយនីតិបុគ្គលជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ |

| | | | | |
|---|---|---|---|---|
| | | គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។<br>ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិអាចធ្វើការត្រួតពិនិត្យ<br>និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋា<br>ភិបាល ។ | ~~ក្នុងករណីចាំបាច់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ~~<br>~~ឬអាជ្ញាធរសវនកម្មជាតិអាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។~~ | បន្ថែមលើកាតព្វកិច្ចជូនដំណឹងទៅក្រសួងអំពីលេខគណនីធនាគារ បន្ទុករបាយការណ៍ បានធ្វើឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបារម្ភថាតើការយករបាយការណ៍គ្រាន់តែដើម្បីតាមដាន ឬចាប់ពិរុទ្ធ?<br>បើធ្វើឱ្យភ័យយ៉ាងនេះ<br>គឺច្បាស់ណាស់ថាប៉ះពាល់ដល់សិទ្ធិឯកជន និងស្វ័យភាពបុគ្គល។ កាតព្វកិច្ចរបាយការណ៍ជាធម្មតាលុះត្រាតែសមាគម ឬអង្គការនោះចុះអនុស្សរណៈជាមួយស្ថាប័នរដ្ឋណាមួយ។<br>ជាក់ស្តែងតាមផ្លូវច្បាប់ និងលក្ខន្តិកៈជាទូទៅ សមាគម<br>និងអង្គការមិនមែនរដ្ឋាភិបាលមិនមែនជាស្ថាប័នចំណុះឱ្យក្រសួងមហាផ្ទៃឡើយជាធម្មតាមិនមានកាតព្វកិច្ចរាយការណ៍គ្រប់សកម្មភាពរួមទាំងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដូចមាត្រា ២៥ តម្រូវនោះទេ។ ជាមួយគ្នានេះ សម្តេចក្រឡាហោម ស ខេង ក៏បានលើកមកបញ្ជាក់រួចហើយថា<br>“ក្រសួងមហាផ្ទៃមិនមែនជាថ្នាក់ដឹកនាំសមាគម ឬអង្គការទេ គឺគ្រាន់តែជាដៃគូរជាមួយគ្នាប៉ុណ្ណោះ។”<br>ប្រសាសន៍របស់សម្តេចក្រឡាហោម បានន័យថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល |

| | | | | |
|---|---|---|---|---|
| | | | | ជាអង្គការឯករាជ្យ អព្យាក្រឹតក្នុងរឿងគណបក្សនយោបាយ មានស្វ័យភាពក្នុងការដឹកនាំ គ្រប់គ្រង និងមានតួនាទីសំខាន់ជាដៃគូរបស់ រដ្ឋាភិបាល។<br><br>អ្វីដែលសំខាន់នោះស្ថាប័នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គឺជាស្ថានប័នដែលឯករាជ្យពីស្ថាប័នរដ្ឋ មិនចាំបាច់ត្រូវរាយការណ៍គ្រប់សកម្មភាពដែលខ្លួនបានធ្វើនោះទេ។ ជាក់ស្តែង សម្តេចបានសម្រេចនៅក្នុងសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃលេខ ២០០៦ សជណ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមិនចាំបាច់ឱ្យសមាគម និងអង្គការជូនដំណឹងក្នុងការធ្វើសកម្មភាពផ្សេងៗនៅមូលដ្ឋាន នេះជាផ្នែកមួយនៃការផ្តល់ស្វ័យភាព ចុះហេតុអ្វីត្រូវចាំបាច់តម្រូវឱ្យមានកាតព្វកិច្ចធ្វើរបាយការណ៍តាមមាត្រា២៥នេះទៀត។ បើកថាខណ្ឌទី១ និងទី៣ នៃមាត្រា២៥ នេះនៅតែរក្សាទុកការតម្រូវឱ្យធ្វើរបាយការណ៍នោះ វាជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់សមាគម ឬអង្គការយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យបាត់ស្វ័យភាពរបស់នីតិបុគ្គលសមាគម ឬអង្គការជាមិនខាន។ |

| | | | | |
|---|---|---|---|---|
| ១១ | មាត្រា ២៦ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។ មុននឹងផ្អាសកម្មភាព សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវធ្វើបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៥នៃច្បាប់ នេះ ។<br><br>សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន ។ | ~~សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។ មុននឹងផ្អាសកម្មភាព សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវធ្វើបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៥នៃច្បាប់នេះ ។~~<br><br>សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន ។ | វាក្យស័ព្ទ *ផ្អាក* “*Suspend*” អាចមានន័យថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ អស់ថវិកាសម្រាប់ដំណើរការ ឬផុតគម្រោង ក្នុងអំឡុងពេលជាក់លាក់ ឬមិនជាក់លាក់ណាមួយ (១ឆ្នាំ ឬ៦ ខែ ជាដើម ។ល។<br><br>ចំណែកពាក្យរំលាយ “de-operation/ dissolve” បិទដំណើរការប្រតិបត្តិការ គឺសំដៅទៅលើការស្នើសុំបិទប្រត្តិបត្តិការ ឬលុបឈ្មោះ សមាគម និងអង្គការ មិនមែនរដ្ឋាភិបាល ចេញពីបញ្ជីមានលក្ខណៈជាអចិន្ត្រៃយ៍។<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកអាចផ្អាកសកម្មភាពរបស់ខ្លួនដោយមិនចាំបាច់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃទេ ព្រោះថានីតិបុគ្គលជាសមាគម និងអង្គការសង្គមស៊ីវិលគឺបង្កើតឡើងក្នុងរូបភាពធ្វើការស្ម័គ្រចិត្ត និងបម្រើឱ្យផលប្រយោជន៍សហគមន៍ជាក់លាក់ណាមួយ ក្នុងគោលបំណងជួយបំពេញកង្វះខាតរបស់រដ្ឋាភិបាល។ ការបន្តសកម្មភាពឬផ្អាកមិនទៀងទាត់ គឺអាស្រ័យលើពេលវេលា ធនធានដែលខ្លួនរកបាន។ |

| | | | | |
|---|---|---|---|---|
| ១២ | មាត្រា ២៧ | សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលបរទេសអាចផ្អាកសកម្មភាពបានដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ មុននឹងផ្អាកសកម្មភាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២៥ នៃច្បាប់នេះ ។<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសមុននឹងបញ្ចប់សុពលភាពអនុស្សារណៈត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន ។ | ~~*សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលបរទេសអាចផ្អាកសកម្មភាពបានដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ មុននឹងផ្អាកសកម្មភាពសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២៥ នៃច្បាប់នេះ ។*~~<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសមុននឹងបញ្ចប់សុពលភាពអនុស្សារណៈត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន ។ | វាក្យស័ព្ទ *ផ្អាក* *“Suspend”* អាចមានន័យថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ អស់ថវិកាសម្រាប់ដំណើរការ ឬផុតគម្រោងក្នុងអំឡុងពេលជាក់លាក់ ឬមិនជាក់លាក់ណាមួយ (១ឆ្នាំ ឬ៦ ខែ ជាដើម ។ល។<br><br>ចំណែកពាក្យរំលាយ “de-operation/ dissolve” បិទដំណើរការប្រតិបត្តិការ គឺសំដៅទៅលើការស្នើសុំបិទប្រត្តិបត្តិការ ឬលុបឈ្មោះ សមាគម និងអង្គការ មិនមែនរដ្ឋាភិបាល ចេញពីបញ្ជីមានលក្ខណៈជាអចិន្ត្រៃយ៍។<br><br>សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលបរទេសអាចផ្អាកសកម្មភាពបានដោយមិនចាំបាច់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ព្រោះថានីតិបុគ្គលជាសមាគម និងអង្គការសង្គមស៊ីវិលគឺបង្កើតឡើងក្នុងរូបភាពធ្វើការស្ម័គ្រចិត្ត និងបម្រើផលប្រយោជន៍ឱ្យសហគមន៍ជាក់លាក់ណាមួយ ក្នុងគោលបំណងជួយបំពេញកង្វះខាតរបស់រដ្ឋាភិបា |

| | | | | |
|---|---|---|---|---|
| | | | | ល។ ការបន្តសកម្មភាពឬផ្អាកមិនទៀងទាត់ គឺអាស្រ័យលើពេលវេលា ធនធានដែលខ្លួនរកបាន។ |
| ១៣ | មាត្រា ៣០ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា ១០ ឬ មាត្រា ២៤ ឬកថាខណ្ឌទី១ ឬ កថាខណ្ឌទី ២ នៃមាត្រា២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្ដោះអាសន្នរយៈពេលយ៉ាងយូរ ៩០(កៅសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។<br><br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានអនុវត្តតាមមាត្រា ១០ (ដូចសំណើរបស់អង្គការសង្គមស៊ីវិល) ~~ឬមាត្រា ២៤ ឬកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃមាត្រា ២៥~~ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ ថ្ងៃនៃថ្ងៃធ្វើការ ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្ដោះអាសន្នរយៈពេលយ៉ាងយូរ ៩០ ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្តក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី ។<br>ស្នើលុបកថាខណ្ឌទី៣ខាងក្រោម៖<br>~~សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរ~~ | មាត្រា ៣០ នេះ មានជាច្រើនបទល្មើសដែលបង្កប់នៅក្នុងនោះ កថាខណ្ឌទី២ និងទី៣ ជាចំណុចដែលស្នើសុំធ្វើវិសោធនកម្ម។<br><br>កថាខ័ណ្ឌទី២៖ លក្ខន្តិកៈ គឺជាការងារផ្ទៃក្នុងរបស់អង្គការមានស្វ័យភាពក្នុងការគ្រប់គ្រង ចាត់ចែង ធ្វើ ឬមិនធ្វើ សម្រេច ឬមិនសម្រេច ដែលមិនគួរក្លាយជាមូលដ្ឋានសម្រាប់ចោទជាបទល្មើសហើយនាំទៅដល់ការសម្រេចដោយតុលាការក្នុងការរំលាយសមាគម អង្គការនោះទេ។ ខ្លឹមសារទូទៅច្បាប់នេះក៏មិនបានការពារសមាគមឬអង្គការក្រៅរដ្ឋាភិបាលជាតិ ឬអន្តរជាតិ (នីតិបុគ្គល) ឲ្យរួចផុតពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តជាបទល្មើសនៅក្នុងច្បាប់ផ្សេងៗ ទៀតជាធរមានដែរ។<br><br>កថាខណ្ឌទី៣៖ សកម្មភាពដែលប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្ដាប់ធ្នាប់សាធារណៈ ឬបង្ករនូវភាពអន្តរាយដល់សន្តិសុខជាតិ |

| | | | | |
|---|---|---|---|---|
| | | កៈរបស់ខ្លួន<br>ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ<br>ឬផ្អាកសកម្មភាពជាបណ្តោះអាសន្នដោយទុករយៈពេលយ៉ាងយូរ<br>៣០(សាមសិប)ថ្ងៃ។<br>ក្នុងករណីនៅតែមិនព្រមអនុវត្ត<br>ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។<br><br>ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម<br>ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា<br>ដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព<br>និងសណ្តាប់ធ្នាប់សាធារណៈ<br>ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។ | ~~*បស់ខ្លួន*~~<br>~~*ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ*~~<br>~~*ឬផ្អាកសកម្មភាពជាបណ្តោះអាសន្នដោយទុករយៈពេលយ៉ាងយូរ*~~<br>~~*៣០(សាមសិប)ថ្ងៃ។*~~<br>~~*ក្នុងករណីនៅតែមិនព្រមអនុវត្ត*~~<br>~~*ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។*~~<br><br>~~*ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម*~~<br>~~*ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។*~~ | ឯកភាពជាតិ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គម ត្រូវបានហាមឃាត់ដោយរដ្ឋធម្មនុញ្ញ។ ក៏ប៉ុន្តែ អំពើទាំងនោះត្រូវបានការពារដោយច្បាប់ផ្សេងៗ ហើយក៏មានកំណត់ជាបទល្មើសមួយចំនួន នៅក្នុងក្រមព្រហ្មទណ្ឌហើយដែរ។<br>ការដាក់ទណ្ឌកម្មគួរតែកំណត់នូវសកម្មភាពជាក់លាក់ មិនមែនចែងជាទូទៅបែបនេះទេ។ |

| | | | | |
|---|---|---|---|---|
| ១៤ | មាត្រា ៣១ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានសិទ្ធិប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការផាកពិន័យទៅតុលាការ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេច ។ | សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានសិទ្ធិប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការផាកពិន័យទៅ*សាលាឧទ្ធរណ៍* ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេច ។ | ដោយសារវិវាទនៅក្នុងច្បាប់នេះ គឺធ្វើរវាងក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សមាគម ឬអង្គការជាតិ ឬអន្តរជាតិ ប៉ុន្តែច្បាប់បានបញ្ជូនឲ្យថៅក្រមសាលាដំបូង រួចប្ដឹងឧទ្ធរណ៍ ឬដល់តុលាការកំពូលដែលជាទូទៅត្រូវចំណាយពេល និងធនធានច្រើន និងអាចហួសរយៈពេលគំរោងកម្មវិធីសង្គម ដែលមានជាមួយម្ចាស់ជំនួយ។ ម៉្យាងវិញទៀតការបញ្ឈប់សកម្មភាព ការបដិសេធការចុះបញ្ជី និងការផាពិន័យគឺធ្វើឡើងដោយរដ្ឋបាលថ្នាក់ជាតិ ដូចនេះការប្ដឹងទៅសលាឧទ្ធរណ៍គឺមានលក្ខណៈសមស្របជាង។ |
| ១៥ | មាត្រា ៣២ | អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាល សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវពិន័យជាប្រាក់ ៥ ០០០ ០០០ រៀល ទៅ ១០ ០០០ | ~~*អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាល សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវពិន័យជាប្រាក់ ៥ ០០០ ០០០ រៀល ទៅ ១០ ០០០ ០០០ រៀលដោយក្រសួងមហាផ្ទៃ ។*~~ | ការកំណត់ថារាល់សកម្មភាពរបស់ក្រុមមនុស្សដែលបាន និងកំពុងប្រព្រឹត្តលើកិច្ចការមនុស្សធម៌ដែលគ្មានប៉ះពាល់អ្វីសោះដល់សណ្ដាប់ធ្នាប់សាធារណៈ បែរជាត្រូវបានអាជ្ញាធរគិតថាអំពើខុសច្បាប់ វាគឺជាការ រំលោភបំពានធ្ងន់ធ្ងរដល់សិទ្ធិនៃការជួបជុំប្រមូលផ្ដុំ ដែលត្រូវបាន ធានាដោយរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែល |

| | | | | |
|---|---|---|---|---|
| | | ០០០ រៀលដោយក្រសួងមហាផ្ទៃ ។ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការដើម្បីចាត់វិធានការតាមច្បាប់ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។<br><br>បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាពហើយនៅតែបន្តធ្វើសកម្ម ភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ | *ក្នុងករណីនៅតែបន្តធ្វើសកម្មភាពទៀតអាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការដើម្បីចាត់វិធានការតាមច្បាប់ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។*<br><br>*បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាពហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។* | កម្ពុជាជាប្រទេសហត្ថលេខី និងមានកាតព្វកិច្ចត្រូវអនុវត្ត និងគោរព អោយបានខ្ជាប់ខ្ជួន។ |
| ១៦ | មាត្រា ៣៥ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអាចបញ្ចប់សុពលភាពអនុស្សារណៈក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសអនុវត្តមិនបានត្រឹមត្រូវតាមអនុស្សារណៈដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអាចបញ្ចប់សុពលភាពអនុស្សារណៈក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសអនុវត្តមិនបាន ត្រឹមត្រូវតាមអនុស្សារណៈដែលចុះជាមួយក្រសួងការបរទេស | ខ្លឹមសារនៃមាត្រានេះ គឺទូលាយខ្លាំងពេកដែលអនុញ្ញាតអោយស្ថាប័នមានសមត្ថកិច្ចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបកស្រាយច្បាប់ និងសម្រេចអំពីការលុបឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចេញពីបញ្ជី។ ដោយសារវាជាប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ដូច្នេះខ្លឹមសារនៃច្បាប់ |

| | | | | |
|---|---|---|---|---|
| | | ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។ | និងសហប្រតិបត្តិការអន្តរជាតិ *លុះត្រាតែតុលាការសម្រេចស្ថាពរបញ្ជាក់ថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ។* | ត្រូវកំណត់អោយបានច្បាស់លាស់អំពីសកម្មភាពនៃបទល្មើលក្នុងគោលបំណងដើម្បីកំណត់អំពីសង្គតភាពនៃការបកស្រាយច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ។ ការចែងមិនច្បាស់លាស់និងអាចធ្វើការបកស្រាយបានតាមចិត្ត ដោយការប្រើឆន្ទានុសិទ្ធិផ្ទាល់ខ្លួនរបស់មន្ត្រីអនុវត្តច្បាប់ វាគឺជាការគ្រោះថ្នាក់សម្រាប់ការអនុវត្តច្បាប់។ |